01298880

D191/4

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

ភាគីដាក់ឯកសារ: *អ្នកមិនមែនជាភាគីនៃរឿងក្តី*

ដាក់ជូន: ការិយាល័យសហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦

ទំព័រ:

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jun-2016, 13:26
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណារបស់*អ្នកមិនមែនជាភាគីនៃរឿងក្តី*ក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤**

---

**<u>ដាក់ដោយ៖</u>**

***អ្នកមិនមែនជាភាគីនៃរឿងក្តី***

Catherine DRUMMOND
Philippa WEBB
Dapo AKANDE

**<u>ផ្ញើជូន៖</u>**

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**

អាង ឧត្តម

Michael G. KARNAVAS

**ការិយាល័យរដ្ឋបាល**

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ហុង គីមសួន

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

សំ សុគង់

ទី ស្រីនណា

វ៉ែន ពៅ

Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Bernabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

I. **សេចក្តីផ្តើម**

1. សេចក្តីអញ្ជើញឱ្យដាក់សារណាលើករណី "ថាតើអនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលត្រូវបានអនុវត្តជាធរមាននៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធខ្លួនឯងអាចចាត់ទុកជាការវាយប្រហារធ្វើឡើងសំដៅប្រឆាំងនឹងប្រជាជនស៊ីវិលដែរឬទេសម្រាប់គោលបំណងនៃមាត្រានៅក្នុងច្បាប់ អ.វ.ត.ក"។ យើងខ្ញុំសូមដាក់ជូននូវសេចក្តីសន្និដ្ឋានដូចខាងក្រោម៖

ក. ក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ៖

i. សមាជិកនៃកងកម្លាំងប្រដាប់អាវុធនៃរដ្ឋអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិប៉ុន្តែមិនអាចជាគោលដៅតែមួយគត់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេប្រសិនបើមិនមានការវាយប្រហារក្នុងទ្រង់ទ្រាយធំលើប្រជាជនស៊ីវិល។

ii. ការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជាករណីលើកលែងដោយហេតុថាវាពុំចាំបាច់ធ្វើឡើងចំពោះប្រជាជនស៊ីវិលនោះឡើយអនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ១៩៧៥ ហើយ*ធាតុផ្សំទូទៅ*នៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក គួរត្រូវបកស្រាយយោងតាមលក្ខខណ្ឌបែបនេះ និង

ខ. ក្នុងអំឡុងពេលនៃសន្តិភាព

i. សមាជិកនៃកងកម្លាំងប្រដាប់អាវុធអាចជាគោលដៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដោយហេតុថាគ្រប់បុគ្គលទាំងអស់គឺជាជនស៊ីវិលក្នុងករណីពុំមានជម្លោះប្រដាប់អាវុធ។

2. ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចដែល អ.វ.ត.ក បានចោទប្រកាន់ប្រាកដជាត្រូវបានចែងហាមឃាត់ដោយច្បាប់អន្តរជាតិដែលអនុវត្តជាធរមាននៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩[1]។ ការបង្កើតនូវច្បាប់ទំនៀមទំម្លាប់អន្តរជាតិទាមទារនូវភ័ស្តុតាងបង្ហាញអំពីការអនុវត្តរបស់រដ្ឋ និង*ទស្សនៈច្បាប់*[2]។ អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក បានលើកឡើងថា ដោយពិចារណាឃើញនូវ

---

[1] *សំណុំរឿង ០០១ សាលដីកា* ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ("សាលដីកា*លើសំណុំរឿង ០០១*") កថាខណ្ឌ ៩៨-១០០។

[2] *សំណុំរឿង ០០១ សាលដីកា* កថាខណ្ឌ ៩៣ (ការអនុវត្តរបស់រដ្ឋ "ដែលមានលក្ខណៈទូលាយ និងឯកភាព")។ Wood, Second report, UN Doc A/CN.4/762 ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ កថាខណ្ឌ ២១-២៣, កថាខណ្ឌ ៥២-៥៩ (ការអនុវត្តរបស់រដ្ឋ "ជារួម និងស៊ីសង្វាក់គ្នា")។

ការលំបាកក្នុងការចោទប្រកាន់ឧក្រិដ្ឋកម្មអន្តរជាតិ លក្ខខណ្ឌតម្រូវនៃ*ទស្សនៈច្បាប់*អាចមានលក្ខណៈសំខាន់ជាងទម្លាប់អនុវត្តក្នុងការចោទប្រកាន់រដ្ឋ[3]។

## II. ក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ

### ក. សមាជិកនៃកងកម្លាំងប្រដាប់អាវុធគឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

3. អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានទទួលស្គាល់យ៉ាងច្បាស់លាស់ថា អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអនុវត្តជាធរមាននៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ សមាជិកនៃកងកម្លាំងប្រដាប់អាវុធអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[4]។ ចំណុចនេះកើតចេញពីចំណុចខុសគ្នារវាងលក្ខខណ្ឌតម្រូវនៅក្នុងមាត្រា ៥ ដែលចែងថាការវាយប្រហារត្រូវ "ប្រឆាំងទៅលើប្រជាជនស៊ីវិល" និងជាជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនោះ។ ដើម្បីចាត់ទុកជា "ប្រជាជនស៊ីវិល" ជនជាគោលដៅទាំងឡាយត្រូវតែប្រជាជន "ច្រើនលើសលុប" ប៉ុន្តែត្រឹមតែវត្តមាននៃយុទ្ធជននៅក្នុងចំណោមប្រជាជនមិនអាចប្រែប្រួលលក្ខណៈរបស់វានោះទេ[5]។ គេពុំឃើញមានលក្ខខណ្ឌតម្រូវណាមួយដែលចែងថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនោះគឺជាជនស៊ីវិលនោះទេ[6]។

4. ជនទាំងឡាយដែលពុំមែនជាជនស៊ីវិលដូចជាឈ្លើយសឹកសង្គ្រាម និងជនទាំងឡាយដែលក្លាយជា*ជនបោះបង់ការប្រយុទ្ធ*ត្រូវបានចាត់ទុកថាជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅមុនឆ្នាំ១៩៧៥។ រឿងក្តី*មេបញ្ជាការជាន់ខ្ពស់*ជាប់ពាក់ព័ន្ធនឹងការបំពានលើឈ្លើយសឹកសង្គ្រាម និងកងកម្លាំងរបស់សម្ព័ន្ធមិត្តត្រូវបានចោទប្រកាន់ចាត់ទុកជាឧក្រិដ្ឋកម្មសង្គ្រាម *និង*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[7]។ រឿងក្តី*ក្រស្ទង់*[8] រឿងក្តី*Barbie*[9] រឿងក្តី*Touvier*[10] និងរឿងក្តី*យូហ្គោស្លាវី-អ៊ីតា*

---

[3] *សំណុំរឿង ០០១ សាលដីកា* កថាខណ្ឌ ៩៣។

[4] *សំណុំរឿង ០០១ សាលក្រម* ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ("សាលក្រម*លើសំណុំរឿង ០០១*") កថាខណ្ឌ ៣១១។ *សំណុំរឿង ០០២/០១ សាលក្រម* ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ("សាលក្រម*លើសំណុំរឿង ០០២/០១*") កថាខណ្ឌ ១៨៧។

[5] *សំណុំរឿង ០០១ សាលក្រម* កថាខណ្ឌ ៣០៥-៣០៦។ *សំណុំរឿង ០០២/០១ សាលក្រម* កថាខណ្ឌ ១៨៣។ ពិធីសារបន្ថែមទីមួយ មាត្រា ៥០(៣)។

[6] *សំណុំរឿង ០០១ សាលក្រម* កថាខណ្ឌ ៣១១។ *Mrkšić សាលដីកា* ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៩ (សាលដីកា *Mrkšić*) កថាខណ្ឌ ៣២។ *Mrkšić សាលដីកា* ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ (សាលដីកា *Mrkšić*) កថាខណ្ឌ ៣០៦-៣១៣។

[7] *Law Reports of the Trials of War Criminals* vol XII, 3, 71។

[8] *Law Reports of the Trials of War Criminals* vol XIV, 541-546។

[9] *Barbie,* 78 ILR 124។

*លី*[11]ដែលត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចំពោះអំពើដែលអ្នកប្រយុទ្ធតស៊ូ យុទ្ធជនដែលបានក្លាយជា *ជនបោះបង់ចោលការប្រយុទ្ធ*និងឈ្លើយសឹកសង្គ្រាមគឺជាជនរងគ្រោះ។ នៅក្នុងរឿងក្តី *P និងអ្នកផ្សេងទៀត*[12] រឿងក្តី *R*[13] *និង*រឿងក្តី *H*[14] តុលាការកំពូលនៅក្នុងតំបន់ដែលកាន់កាប់ដោយចក្រភពអង់គ្លេសបានពិចារណាថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ប្រទេសអាល្លឺម៉ង់*ខ្លួនឯង*ចំពោះការប៉ុនប៉ងការរត់ចោលជួរ ការប្រមាថថ្នាក់ដឹកនាំ និងការផ្តត់ផ្គង់អត្តសញ្ញាណបណ្ណនៅក្នុងកាលៈទេសៈសកម្មភាពដែលត្រូវបានធ្វើឡើងប្រឆាំងនឹងជនរងគ្រោះគឺជាផ្នែកធំមួយនៃរបបណាហ្ស៊ីពោរពេញដោយយុត្តិធម៌ដ៏ឃោរឃៅ និងការភ័យខ្លាច។

5. បញ្ហាចោទលេចឡើងគឺថាតើការកំណត់គោលដៅដោយចេតនាលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធអាចបង្កើតក្នុងលក្ខណៈសត្យានុម័តជាផ្នែកមួយនៃការវាយប្រហារដ៏ទូលំទូលាយលើប្រជាជនជនស៊ីវិលដែរឬយ៉ាងណា។ បញ្ហាចោទនេះត្រូវបានឆ្លើយតបតាមរយៈបទដ្ឋានមួយដែលលើកឡើងអំពីចំណងទាក់ទងរវាងអំពើនោះជាមួយនឹងការវាយប្រហារលើប្រជាជនស៊ីវិល[15]។ នៅក្នុងរឿងក្តី *Mrkšić* ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ទទួលស្គាល់ថា បុគ្គលដែលពុំមែនជាជនស៊ីវិលអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក៏ដោយក៏តុលាការនេះបានតម្កល់ការសម្រេចឱ្យរួចផុតពីបទចោទដដែលដោយហេតុថាអំពើនានាដែលជាបញ្ហាចោទទាំងនោះត្រូវបានធ្វើឡើងសំដៅប្រឆាំងនឹងក្រុមបុគ្គលជាក់លាក់ដោយផ្អែកលើមូលដ្ឋាននៃការចូលរួមពាក់ព័ន្ធនៅក្នុងកងកម្លាំងប្រដាប់អាវុធនៃប្រទេសក្រូអាដ។ ដូច្នេះ បុគ្គលទាំងនេះត្រូវចាត់ទុកក្នុងលក្ខណៈផ្សេងពីប្រជាជនស៊ីវិលនៅក្នុងរដ្ឋ Vukovar ហើយអំពើទាំងនេះមិនមានចេតនាបង្កើតជាផ្នែកមួយនៃការវាយប្រហារក្នុងទ្រង់ទ្រាយធំប្រឆាំងនឹងប្រជាជនស៊ីវិលនោះទេ។ អាស្រ័យហេតុ

---

[10] *Touvier,* 100 ILR 338។

[11] *គណកម្មការឧក្រិដ្ឋកម្មសង្គ្រាមនៃ អ.ស.ប* (*គណកម្មការឧក្រិដ្ឋកម្មសង្គ្រាមនៃ អ.ស.ប*) *បទចោទយូហ្គោស្លាវី-អ៊ីតាលី នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ* ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៤៦ កថាខណ្ឌ VII, X, XIII, XV-XVI។

[12] Casses *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (*បោះពុម្ពលើកទីពីរ ឆ្នាំ២០០៨*) (“Casses *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*”) *១១៩*។

[13] Casses *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ១១៩*។

[14] Casses *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ១២០*។

[15] *សាលក្រមលើសំណុំរឿង ០០១ កថាខណ្ឌ ៣១៨*។

នេះ វាគ្មានទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទជាមួយនឹងការវាយប្រហារជាលក្ខណៈប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលនោះឡើយ[16]។

6. ហេតុដូច្នេះ វាបង្ហាញឱ្យឃើញថា ប្រសិនបើសមាជិកនៃកងកម្លាំងប្រដាប់អាវុធត្រូវបានកំណត់គោលដៅដោយផ្អែកលើមូលដ្ឋានដូចគ្នានឹងជនស៊ីវិលថាជាផ្នែកមួយនៃការវាយប្រហារក្នុងទ្រង់ទ្រាយធំប្រឆាំងនឹងប្រជាជនស៊ីវិលច្រើនលើសលុប ពួកគេអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ករណីនេះនឹងបង្ហាញច្បាស់នៅក្នុងរឿងក្តីនានា ឧទាហរណ៍ ដែលអំពើនានាប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងជនរងគ្រោះត្រូវបានជម្រុញដោយចេតនារើសអើងដូចគ្នា។

## ខ. សមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ*ខ្លួនឯង*គឺជា*គោលដៅ*នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

7. ការអានឱ្យបានហ្មត់ចត់លើអនុសញ្ញាទីក្រុងហ្សឺណែវ និងពិធីសារបន្ថែមបង្ហាញឱ្យឃើញថា ឧក្រិដ្ឋកម្មសង្គ្រាម*ខ្លះ*អាចត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ*ខ្លួនឯង*[17]។ ទោះបីជាយ៉ាងនេះក៏ដោយ នត្ថិភាពនៃការការពារទូទៅចំពោះសមាជិកនៃកងកម្លាំងប្រដាប់អាវុធក៏ដូចជាកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋខ្លួនឯង[18] និងការវិវឌ្ឍនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិបានជំរុញឱ្យមានការលើកឡើងទឡ្ហីករណ៍គាំទ្រចំពោះការពង្រីកនិយមន័យនៃពាក្យ "ជនស៊ីវិល" និង "ប្រជាជនស៊ីវិល" ថាវាគ្របដណ្តប់រួមទាំងកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ*ខ្លួនឯង*ផងដែរ[19]។

8. បញ្ហានេះលេចឡើងនៅក្នុងបណ្តឹងសាទុក្ខ *Mrkšić*។ ដោយសំអាងលើរឿងក្តីក្រោយសង្គ្រាមលោកលើកទីពីរគឺរឿងក្តី *P និងអ្នកផ្សេងទៀត* រឿងក្តី *R និង*រឿងក្តី *H* ដែលរឿងក្តីទាំងបីនេះរួមបញ្ចូលការវាយប្រហារប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ*ខ្លួនឯង* រដ្ឋអាជ្ញាបានផ្តល់ទឡ្ហីករណ៍ថានិយមន័យនៃពាក្យ "ជនស៊ីវិល" នៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ("ច្បាប់មនុស្សធម៌អន្តរជាតិ")

---

[16] *Mrkšić សាលដីកា* កថាខណ្ឌ ៣២, ៣២, ៤២-៤៣។

[17] *ប្រៀបធៀបមាត្រា ៧៥ នៃពិធីសារបន្ថែមទីមួយ ("នៅក្នុងអំណាចរបស់ភាគី") និងមាត្រា ៣ រួម ("បុគ្គលដែលពុំបានចូលរួមសកម្មនៅក្នុងការប្រទូស្តរ៉ាយ") ជាមួយនឹងមាត្រា ៤ក នៃអនុសញ្ញាទីក្រុងហ្សឺណែវទីបី (នៅក្នុង "អំណាចនៃខ្មាំង")។ សូមមើលផងដែរ Ntaganda សេចក្តីសម្រេចលើការសម្រេចតម្កល់បទចោទ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៤ កថាខណ្ឌ ៧៧-៨០*។

[18] *Pilz* (17 ILR 391) *និង Motosuke* (15 IHR 682) *ដែលក្នុងនោះការបញ្ជាឱ្យសម្លាប់បុគ្គលដែលបានចូលរួមជាមួយនឹងកងកម្លាំងកាន់កាប់ពុំចាត់ទុកជាឧក្រិដ្ឋកម្មសង្គ្រាមនោះទេ។ Sesay សាលក្រម ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ១៤៥១-១៤៥៤*។

[19] *ខ. Ambos និង* Wirth "*ច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនាពេលបច្ចុប្បន្ន*" (2002) 13 *CLF* 1, 24-25។ Werle *និង* Jeβberger *គោលការណ៍នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (បោះពុម្ពលើកទីបី ឆ្នាំ២០១៤)* ("Werle *គោលការណ៍*") *កថាខណ្ឌ ៨៨៨*។ *Kupreškić* សាលក្រម ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ (សាលក្រម *Kupreškić*) កថាខណ្ឌ ៥៤៧។

មិនអាចយកមកអនុវត្តបានដោយផ្ទាល់នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយនិយមន័យនៃ "ជនស៊ីវិល" គួរក្តោបរួមបុគ្គលទាំងអស់ដែលមិនចូលរួមដោយផ្ទាល់នៅក្នុងការប្រទូស្តរាយផងដែរ[20]។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានច្រានចោលទឡ្ហីករណ៍នេះ ហើយជាពិសេសចំពោះឋានៈទំនៀមទម្លាប់នៅក្នុងឆ្នាំ១៩៧៥ តុលាការនេះបានពិចារណាឃើញថា យុត្តិសាស្ត្រនៅក្រោយសង្គ្រាមលោកលើកទីពីរគឺជាឯកសារសំអាងសម្រាប់ទ្រឹស្តីថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធអាច *ជនរងគ្រោះ*នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិប៉ុន្តែ *មិនអាចជា*ទ្រឹស្តីថា ពួកគេអាចជា *ជនស៊ីវិល*នោះឡើយ[21]។ ជំហរនេះត្រូវបានតម្កល់ដោយ *Pilz* ដែលនៅក្នុងរឿងក្តីនេះតុលាការហូឡង់ដ៏បានសម្រេចថា ការបដិសេធការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងការសម្លាប់ពលរដ្ឋហូឡង់ដ៏ដោយវេជ្ជបណ្ឌិតយោធាអាល្លឺម៉ង់ដែលពលរដ្ឋរូបនេះបានចូលបម្រើនៅក្នុងជួរកងកម្លាំងអាល្លឺម៉ង់ពុំចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេដោយសារជនរងគ្រោះគឺជាសមាជិកនៃកងកម្លាំងរដ្ឋកាន់កាប់ ដូច្នេះ ជនរងគ្រោះពុំមែនជាជនស៊ីវិលនោះឡើយ[22]។

9. យើងឃើញមានយុត្តិសាស្ត្រគាំទ្រតិចតួចចំពោះការចាត់ទុកកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ*ខ្លួនឯង* ជា "ជនស៊ីវិល" នៅក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ[23]។ ទ្រឹស្តីទូទៅក៏អាចជាបញ្ហាផងដែរ លើករណីជាក់ស្តែងរួមទាំងករណីដែលថា រដ្ឋមានកាតព្វកិច្ចបែងចែកឲ្យដាច់រវាងកងកម្លាំងប្រដាប់អាវុធខ្លួនឯង និងប្រជាជនស៊ីវិល[24]។

10. ទោះបីជាមានហេតុផលស៊ីសង្វាក់គ្នាជាមួយនឹងគោលបំណងជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលចាត់ទុកសមាជិកនៃកងកម្លាំងប្រដាប់អាវុធ*ខ្លួនឯង*គឺជា "ជនស៊ីវិល" ហេតុដូច្នេះ ពួកគេអាចជា *គោលដៅ*នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក៏ដោយ ក៏ការខ្វះនូវភ័ស្តុតាងច្បាស់

---

[20] *Martić* *សារណាបណ្តឹងសាទុក្ខរបស់អយ្យការ* ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៧ កថាខណ្ឌ ៤៤-៤៥។ ចំណុចនេះឆ្លុះបញ្ចាំងវិធីសាស្ត្រដែលបានប្រកាន់យកដោយអង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តី ICTR៖ សាលក្រម *Akayesu* ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៥៨២ ប៉ុន្តែ សូមអានផ្ទុយជាមួយនឹង *Bagosora និងអ្នកផ្សេងទៀត* សាលក្រម ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ លេខយោងជើងទំព័រ ២៣៥៣ ដែលដកស្រង់សាលដីកា *Martić*។

[21] *Martić* កថាខណ្ឌ ២៩៨-៣០១, ៣០៩-៣១០។

[22] *Pilz* 17 ILR 391 ។ *គ្មានការពិភាក្សាលើការវាយប្រហារក្នុងលក្ខណៈទូលំទូលាយប្រឆាំងនឹងប្រជាជនស៊ីវិលនោះឡើយ* ។

[23] *នៅក្នុងរឿងក្តី* *Pius Nwaoga* (52 ILR 494) *ម្ចាស់បណ្តឹងសាទុក្ខត្រូវបានសម្រេចឲ្យមានពិរុទ្ធភាពពីបទធ្វើមនុស្សឃាតដែលជាបទឧក្រិដ្ឋក្នុងច្បាប់ជាតិ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចំពោះការសម្រួលដល់ការកាប់សម្លាប់សមាជិកនៃកងទ័ពចក្រភពអង់គ្លេសនៅក្នុងឆ្នាំ១៩៦៩ ក្នុងអំឡុងពេលសង្គ្រាមស៊ីវិលនីហ្សេរីយ៉ា។ គ្មានអង្គហេតុណាមួយត្រូវបានផ្តល់ជូនដែលបង្ហាញអំពីការធ្វើមនុស្សឃាតដែលបានបង្កើតជាផ្នែកមួយនៃការវាយប្រហារក្នុងទ្រង់ទ្រាយទូលំទូលាយលើប្រជាជនស៊ីវិលនោះទេ*។

[24] *ពិធីសារបន្ថែមលើកទីមួយ មាត្រា ៤៤(៣), ៥១(៣)*។

លាស់រាំងមិនឲ្យធ្វើការសន្និដ្ឋានថា ការចាត់ទុកបែបនេះគឺជាទំនៀមទម្លាប់នៅក្នុងឆ្នាំ១៩៧៥។ ទោះបីជាយ៉ាងនេះក្តី សមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋពុំមែនពុំទទួលបានការការពារនៅក្រោមច្បាប់អន្តរជាតិនោះទេ។ រដ្ឋនៅតែមានកាតព្វកិច្ចការពារសិទ្ធិមនុស្សដល់ជនទាំងអស់នោះដដែល។

## គ. ករណីពិសេសនៃការធ្វើទុក្ខបុកម្នេញ

11. គេអាចលើកទឡ្ហីករណ៍បានថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញពុំចាំបាច់ធ្វើឡើងសំដៅប្រឆាំងនឹងប្រជាជនស៊ីវិលនោះទេយោងតាមទំនៀមទម្លាប់នៅក្នុងឆ្នាំ១៩៧៥។ បទប្បញ្ញត្តិនៅក្នុងធម្មនុញ្ញនៃសាលាក្តីយោធាអន្តរជាតិ ("សាលាក្តីយោធាអន្តរជាតិ") និងសាលាក្តីយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ("សាលាក្តីយោធាអន្តរជាតិសម្រាប់ចុងបូព៌ា") ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ និងគោលការណ៍នូរ៉ឹមប៊ឺកឆ្នាំ១៩៥០នៃគណកម្មការនីតិកម្មអន្តរជាតិបានទទួលស្គាល់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចំនួនពីរប្រភេទ ពោលគឺ "ប្រភេទនៃការធ្វើមនុស្សឃាត" និង "ប្រភេទនៃការធ្វើទុក្ខបុកម្នេញ"[25]។ ដោយសារផ្នាក់ "ឬ" ដែលជាផ្នាក់ផ្តាច់ចេញប្រភេទទាំងពីរពីគ្នា មានតែ "ប្រភេទនៃការធ្វើមនុស្សឃាត" តែប៉ុណ្ណោះត្រូវបានកំណត់លក្ខខណ្ឌថា ប្រភេទនៃការធ្វើមនុស្សឃាតនេះត្រូវធ្វើឡើងសំដៅប្រឆាំងនឹងប្រជាជនស៊ីវិល។

12. ជំហរនេះត្រូវបានគាំទ្រដោយលិខិតុបករណ៍ជាហូរហែមក[26]។ គ្មានអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ ឬ អនុសញ្ញាស្តីពីអាប៉ាថេតឆ្នាំ១៩៧៣ ដែលអនុសញ្ញាទាំងពីរទាក់ទងនឹងទម្រង់ជាក់លាក់នៃការធ្វើទុក្ខបុកម្នេញថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[27] សំដៅលើគោលដៅប្រជាជនស៊ីវិលជាក់លាក់ណាមួយនោះទេ។ អនុសញ្ញាទាំងពីរសំដៅតែទៅលើ "បុគ្គល" ឬ "ក្រុម" តែប៉ុណ្ណោះ។ អនុសញ្ញាឆ្នាំ១៩៦៨ស្តីពីភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលនៅតែមានការបែង

---

[25] *ធម្មនុញ្ញ*សាលាក្តីយោធាអន្តរជាតិ មាត្រា ៦(គ)។ ធម្មនុញ្ញសាលាក្តីយោធាអន្តរជាតិសម្រាប់ចុងបូព៌ា មាត្រា ៥(គ)។ ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ មាត្រា II(១)(គ)។ គោលការណ៍នូរ៉ឹមប៊ឺនៃគណកម្មការនីតិកម្មអន្តរជាតិ គោលការណ៍ VI(គ)។ គណកម្មការស្តីពីឧក្រិដ្ឋកម្មសង្គ្រាមនៃ អ.ស.ប *ប្រវត្តិនៃគណកម្មការស្តីពីឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ និងការវិវឌ្ឍនៃច្បាប់សង្គ្រាម* (ឆ្នាំ១៩៤៨) (គណកម្មការស្តីពីឧក្រិដ្ឋកម្មសង្គ្រាមនៃ អ.ស.ប ប្រវត្តិ) ១៧៨។

[26] *សូមអានផ្ទួប សេចក្តីព្រាងឆ្នាំ១៩៥៤ នៃក្រមស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ* (របាយការណ៍នៃគណកម្មការនីតិកម្មអន្តរជាតិ (ឆ្នាំ១៩៥៤) UN Doc A/2693 10។

[27] *សាលក្រមលើសំណុំរឿង ០០១ កថាខណ្ឌ ២៨៨*។ Schabas *ប្រល័យពូជសាសន៍នៅក្នុងច្បាប់អន្តរជាតិ (ឆ្នាំ២០០០) ២៥៤*។

01298887



ចែកដដែលដោយបានយកតាមនិយមន័យនៅក្នុងមាត្រា ៦(គ) នៃធម្មនុញ្ញរបស់សាលាក្ដីយោធាអន្តរជាតិ[28]។

13. គណកម្មការស្ដីពីឧក្រិដ្ឋកម្មសង្គ្រាមនៃ អ.ស.ប បានលើកឡើងថា "ចំពោះប្រភេទនៃការធ្វើមនុស្សឃាតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជាបទល្មើសដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងប្រជាជនស៊ីវិល។ បទល្មើសដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធគឺស្ថិតនៅក្រៅវិសាលភាពនៃប្រភេទមួយនេះ ហើយ*ប្រហែលជា*ក៏នៅក្រៅវិសាលភាពប្រភេទនៃការធ្វើទុក្ខបុកម្នេញផងដែរ"[29]។ អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្ដី ICTY នៅក្នុងរឿងក្ដី *Kupreškić* ពុំបានបញ្ជាក់ច្បាស់លាស់នោះឡើយ។ អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្ដីនេះបានសំអាងលើការកាត់ទោសនៅក្រោយសង្គ្រាមលោកលើកទីពីរដោយបានលើកឡើងថា "អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងករណីនៃការធ្វើទុក្ខបុកម្នេញ ជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិពុំចាំបាច់ជាជនរងគ្រោះនោះឡើយ។ ពួកគេក៏អាចរួមបញ្ចូលទាំងបុគ្គលិកយោធាផងដែរ"[30]។ នេះគឺជាទស្សនៈមួយដែលត្រូវបាន Cassese លើកឡើងជាយូរមកហើយ[31]។

14. អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក បានទទួលយកការបែងចែករវាង "ប្រភេទនៃការធ្វើមនុស្សឃាត" និង "ប្រភេទនៃការធ្វើទុក្ខបុកម្នេញ" នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលត្រូវបានអនុវត្តជាធរមាននៅក្នុងឆ្នាំ១៩៧៥[32] ប៉ុន្តែពុំបានពិចារណាដោយផ្ទាល់ថាតើការធ្វើទុក្ខបុកម្នេញត្រូវតែធ្វើឡើងសំដៅប្រឆាំងនឹងប្រជាជនស៊ីវិលឬក៏យ៉ាងណានោះឡើយ។ ទោះបីជាយ៉ាងនេះក៏ដោយ នៅក្នុងការពិភាក្សាលើច្បាប់ទំនៀមទម្លាប់អន្តរស្ដីពីការធ្វើទុក្ខបុកម្នេញ អង្គជំនុំជម្រះតុលាការកំពូលពុំបានសំដៅលើ "ជនស៊ីវិល" ឬ "ប្រជាជនស៊ីវិល" នោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលគ្រាន់តែបានសំដៅលើ "បុគ្គល" "ជន" និង "ក្រុម" តែប៉ុណ្ណោះ[33]។

15. ស្របតាមគោលការណ៍នីត្យានុកូលភាព ពាក្យពេចន៍គ្រង់ៗនៅក្នុងធម្មនុញ្ញនៃសាលាក្ដីយោធាអន្តរជាតិ ធម្មនុញ្ញនៃសាលាក្ដីយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ និងគោលការណ៍នូរ៉ុមប៊ឺកបង្ហាញថា ផលវិបាកផ្នែកព្រហ្មទណ្ឌនៃការធ្វើទុក្ខបុកម្នេញជនទាំងឡាយ

---

[28] 754 UNTS 73 មាត្រា I(ខ)។

[29] *គណកម្មការស្ដីពីឧក្រិដ្ឋកម្មសង្គ្រាមនៃ អ.ស.ប ប្រវត្តិ ១៧៨ (ការគូសបញ្ជាក់បន្ថែម)*។

[30] *Kupreškić* សាលក្រម ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៥៦៨។

[31] Cassese *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* ១២១។

[32] *សាលដីកាលើសំណុំរឿង ០០១ កថាខណ្ឌ ២៣២-២៣៣, ២៣៨-២៣៩*។

[33] *សាលដីកាលើសំណុំរឿង ០០១ កថាខណ្ឌ ២២៦-២៧៨*។

មិនថាជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ឬ សមាជិកណាមួយនោះទេ អាចប្រមើលមើលឃើញនៅក្នុងឆ្នាំ១៩៧៥ បាន។

16. ដូច្នេះ ប្រសិនបើការធ្វើទុក្ខបុកម្នេញអនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងសមាជិកកងកម្លាំងប្រដាប់អាវុធ តើនិយមន័យនៃការធ្វើទុក្ខបុកម្នេញយោងតាមច្បាប់ទំនៀមទម្លាប់ និងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក មានទំនាក់ទំនងនឹងគ្នាយ៉ាងដូចម្តេចទៅ? *ធាតុផ្សំទូទៅ*នៃមាត្រា ៥ ទាមទារនូវលក្ខខណ្ឌថា ការវាយប្រហារទូទៅ ឬ ជាលក្ខណៈប្រព័ន្ធត្រូវធ្វើឡើងសំដៅប្រឆាំងនឹងប្រជាជនស៊ីវិលចំពោះឧក្រិដ្ឋកម្មទាំងអស់ រួមទាំង ការធ្វើទុក្ខបុកម្នេញផងដែរ។ មាត្រា ៥ មិនអាចតាមអនុភាពប្រតិសកម្មកែប្រែវិសាលភាពនៃការធ្វើទុក្ខបុកម្នេញនៅក្នុងឆ្នាំ១៩៧៥ នោះឡើយ[34] ប៉ុន្តែវាអាចបង្រួមយុត្តាធិការនៃ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[35]។ ខុសពីការកម្រិតយុត្តាធិការផ្សេងទៀតដែលមានគោលបំណងកំហិតយុត្តាធិការតុលាការលើឧក្រិដ្ឋកម្មនានាដែលពិតជាបានកើតឡើងនៅក្នុងស្ថានភាពជាក់លាក់មួយ[36] វាទំនងជាគ្មានយុត្តិកម្មចំពោះ ឬ ចេតនាជាក់លាក់ណាមួយក្នុងការដកការធ្វើទុក្ខបុកម្នេញដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធនៃកម្ពុជាចេញពីយុត្តាធិការរបស់ អ.វ.ត.ក នោះឡើយ[37]។

17. នៅក្នុងកាលៈទេសៈបែបនេះ មាត្រា ៥ ទំនងជាការប៉ុនប៉ងមួយតាមអនុភាពប្រតិសកម្ម ហើយកែប្រែដោយផ្ទុយនឹងច្បាប់នូវនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ដូច្នេះ លក្ខខណ្ឌតម្រូវនៃប្រជាជនស៊ីវិលនៅក្នុង*ធាតុផ្សំទូទៅ*នៅក្នុងមាត្រា ៥ ត្រូវតែបកស្រាយថាមិនអាចអនុវត្តបានចំពោះការធ្វើទុក្ខបុកម្នេញនោះឡើយ។ ការធ្វើទុក្ខបុកម្នេញសមាជិកនៃកងកម្លាំងប្រដាប់អាវុធ[38]អាចចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងឆ្នាំ១៩៧៥។

---

[34] *សាលដីកាលើសំណុំរឿង ០០១ កថាខណ្ឌ ១០០*។

[35] *សាលក្រមលើសំណុំរឿង ០០១ កថាខណ្ឌ ៣១៣-៣១៤*។

[36] *សាលដីកាលើរឿងក្តី Akayesu ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៤៦៤-៤៦៥*។

[37] *របាយការណ៍របស់ក្រុមអ្នកជំនាញកម្ពុជា* UN Doc A/53/850-S/1999/231 ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩ កថាខណ្ឌ ៦៦ (ខ) ៦៨ សូមអានផ្គួបជាមួយនឹង ៦៩។

[38] *អំពើស្របច្បាប់នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិនឹងមិនបង្កើតជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ៖ Gotovina និង Markač* សាលដីកា ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ កថាខណ្ឌ ៩៦ ១១៤។ Werle *គោលការណ៍* កថាខណ្ឌ ៨៩០។

## III. ក្នុងអំឡុងពេលនៃសន្តិភាព

18. ទឡ្ហីករណ៍អាចលើកឡើងថា នៅក្នុងពេលសន្តិភាព សមាជិកនៃកងកម្លាំងប្រដាប់អាវុធអាចជា "ជនស៊ីវិល" ដូច្នេះ ការវាយប្រហារសំដៅប្រឆាំងនឹងពួកគេអាចចាត់ទុកជាការវាយប្រហារសំដៅប្រឆាំងនឹង "ប្រជាជនស៊ីវិល"។ អ.វ.ត.ក បានកំណត់និយមន័យ "ជនស៊ីវិល" នៅក្នុងឆ្នាំ១៩៧៥ ថារួមបញ្ចូលទាំង "បុគ្គលទាំងឡាយដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ឬ មិនមែនជាជនត្រូវបានទទួលស្គាល់ថាជាអ្នកប្រយុទ្ធ" ហើយបានបញ្ជាក់ថា ករណីនេះគឺស្របតាម មាត្រា ៥០ នៃពិធីសារបន្ថែមទីមួយ[39]។ មាត្រា ៥០ នៃពិធីសារបន្ថែមទីមួយកំណត់និយមន័យ "ជនស៊ីវិល" ក្នុងលក្ខណៈអវិជ្ជមានដោយសំដៅលើកងកម្លាំងប្រដាប់អាវុធ*នៃភាគីជម្លោះ*ឬជនទាំងឡាយដែលត្រូវបានចាត់ទុកជាយុទ្ធជន*នៃភាគីជម្លោះ* (នៅក្នុងជម្លោះប្រដាប់អាវុធទាំងអន្តរជាតិ និងជាតិ[40])។ ទោះបីជាពុំមានចំណុចយោងលើ "ភាគីនៃជម្លោះក៏ដោយ" នៅក្នុងការពិភាក្សានៃ អ.វ.ត.ក ក៏មានការសន្និដ្ឋានថា ចេតនាកំណត់និយមន័យឲ្យស្របគ្នាជាមួយនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិមានន័យថា ការកំណត់បែបនេះអនុវត្តចំពោះពាក្យ "ជនស៊ីវិល" ផងដែរ។ ប្រភេទ "ជនស៊ីវិល" និង "យុទ្ធជន" ត្រូវបានគេយល់ឃើញថាមានភាពខុសគ្នា ហើយសំខាន់បំផុតនោះក្នុងគោលបំណងនៃការកំណត់គោលដៅ[41]។ ទំនាក់ទំនងរវាងយុទ្ធជន និងភាគីជម្លោះមានសារសំខាន់ចំពោះការទទួលស្គាល់ពួកគេនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងដំណើរការនៃច្បាប់នេះ។ ទំនាក់ទំនងបរិបទរវាងជនស៊ីវិល និងភាគីជម្លោះមានសារសំខាន់ចំពោះនិយមន័យអវិជ្ជមាននៃ "ជនស៊ីវិល"។

19. នៅក្នុងលក្ខណៈដូចគ្នាដែលថា កងកម្លាំងប្រដាប់អាវុធនៃរដ្ឋមួយដែលមិនចូលរួមនៅក្នុងជម្លោះ អាចមិនមែនជា "យុទ្ធជន" សម្រាប់គោលបំណងនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅក្នុងពេលសន្តិភាព ដោយសារវាគ្មានជម្លោះ គ្មានភាគីជម្លោះ ហេតុដូច្នេះ វាគ្មានយុទ្ធជននោះឡើយ។ នៅពេលអនុវត្តនិយមន័យនៃ "ជនស៊ីវិល" ដោយចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គ្រប់បុគ្គល

---

[39] *សាលក្រមលើសំណុំរឿង ០០១ កថាខណ្ឌ ៣០៤។ សាលក្រមលើសំណុំរឿង ០០២/០១ កថាខណ្ឌ ១៨៥ ដកស្រង់ សាលដីកា* Martić *កថាខណ្ឌ ២៩៧។*

[40] *សាលដីកា* Martić *កថាខណ្ឌ ៣០០។*

[41] *គណកម្មាធិការកាកបាទក្រហមអន្តរជាតិ អត្ថាធិប្បាយលើពិធីសារបន្ថែម កថាខណ្ឌ ១៩១៣-១៩១៤។*

ទាំងអស់នៅក្នុងពេលសន្តិភាពរួមទាំងអ្នកដែលបានបង្កើតជាផ្នែកមួយនៃកងកម្លាំងប្រដាប់អាវុធ បានបំពេញលក្ខណៈជាជនស៊ីវិល[42]។

20. ចំណុចនេះមានការគាំទ្រនៅក្នុងការទស្សនៈជឿជាក់របស់អតីតមេបញ្ជាការរ៉ូម៉ានីមួយរូបចំពោះការធ្វើមនុស្សឃាត ទារុណកម្ម និងការសម្លាប់រង្គាលដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិសម្រាប់ការប្រព្រឹត្តលើអ្នកទោសនយោបាយរួមទាំងសមាជិកនៃយោធាបម្រុងរបស់ប្រទេសរ៉ូម៉ានីផងដែរ នៅក្នុងអំឡុងពេលសន្តិភាពពីឆ្នាំ១៩៥៦ ដល់ ឆ្នាំ១៩៦៣[43]។ គ្មានការបែងចែករវាងជនជាប់ឃុំដោយផ្អែកលើមូលដ្ឋាននៃសមាជិកភាពជាយោធារបស់ពួកគេត្រូវបានធ្វើឡើងនោះទេ។ ស្រដៀងគ្នានេះដែរ សមាជិកមួយរូបនៃរបបផ្តាច់ការយោធារបស់ប្រទេសអាហ្សង់ទីនចន្លោះឆ្នាំ១៩៧៦ ដល់ ឆ្នាំ១៩៨៣ ត្រូវបានសម្រេចឱ្យមានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងករណីដែលយ៉ាងហោចណាស់ជនរងគ្រោះមួយរូបគឺជាសមាជិកបម្រើការងារនៅក្នុងកម្លាំងប្រដាប់អាវុធ ហើយគ្មានការបែងចែកត្រូវបានធ្វើឡើងលើឋានៈនេះឡើយ[44]។ Pinochet ត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះនៅក្នុងប្រទេសអេស្ប៉ាញចំពោះអំពើដែលរួមបញ្ចូលទាំងភេរវកម្មដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិប្រព្រឹត្តឡើងនៅចន្លោះឆ្នាំ១៩៧៣ ដល់ ឆ្នាំ១៩៩០ តាមរយៈអំពើដែលបានដាក់បញ្ចូលនៅក្នុងការបោសសម្អាតផ្ទៃក្នុងយោធា[45]។

21. ទឡ្ហីករណ៍នេះច្រានចោលសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តី ICTR នៅក្នុងរឿងក្តី *Kayishema* ដែលបានលើកឡើងថា និយមន័យនៃ "ជនស៊ីវិល" ឬ "ប្រជាជនស៊ីវិល" ខុសគ្នាអាស្រ័យលើករណីថាតើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានកើតឡើងនៅក្នុងអំឡុងពេល

---

[42] *ដោយសារជំហរនេះអនុវត្តលើនិយមន័យនៃ "ជនស៊ីវិល" វាពុំដូចគ្នានឹងទឡ្ហីករណ៍ដែលត្រូវបានប្រើប្រាស់ដោយ* Cassese *ដែលលើកឡើងថា ដោយសារការវិវឌ្ឍរីកចម្រើននៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ វាលែងមានយុត្តិកម្មទៀតហើយចំពោះលក្ខខណ្ឌតម្រូវដែលថា ការវាយប្រហារត្រូវធ្វើឡើងសំដៅប្រឆាំងនឹងប្រជាជនស៊ីវិលមិនថានៅក្នុងពេលណាក៏ដោយ ប៉ុន្តែជាពិសេសនៅក្នុងពេលសន្តិភាព៖* Cassese *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ១២២។ ជំហរទាំងពីរត្រូវបានលើកឡើងដោយផ្អែកលើគោលការណ៍នៃការបែងចែកដាច់ពីគ្នាដោយគ្មានទំនាក់ទំនងនឹងពេលសន្តិភាព។*

[43] *Vişinescu* តុលាការជាន់ខ្ពស់នៃតុលាការកំពូល និងសាលាឧទ្ធរណ៍របស់ប្រទេសរ៉ូម៉ានី ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៦, ៣, ២៣, ២៦-២៨, ១៩០-១៩១។

[44] "ESMA" (*សាលាបច្ចេកទេសទ័ពជើងទឹក*-GT 3.3.2) *តុលាការព្រហ្មទណ្ឌសហព័ន្ធប៊ុយណូស៊ែរ* ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១, ៧៦៦, ១២៧២-១២៧៣, ១៩៨៦-១៩៨៩។

[45] *សេចក្តីសង្ខេប ១៩/៩៧ នៃបទបញ្ជា "ប្រតិបត្តិការ* Condor" *អំពីភេរវកម្ម និងអំពើប្រល័យពូជសាសន៍ សាលាដំបូង* (Central Court of Instruction) ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨, ១-៥, ៥៨-៦២, ៣៤៩, ៣៥៤។

ជម្លោះប្រដាប់អាវុធ ឬ ក្នុងពេលសន្តិភាព[46]។ ភាពពុំស៊ីសង្វាក់គ្នាផ្ទៃក្នុងនៃ *Kayishema* នៅក្នុងការលើកឡើងថា និយមន័យដ៏ទូលំទូលាយមួយគួរកំណត់លើពាក្យ "ជនស៊ីវិល" ប៉ុន្តែ ការកំណត់ពាក្យនេះក្នុងនិយមន័យចង្អៀតជាងការអនុវត្តជាធរមាននៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិដោយបានដកចេញនូវគតិបាលនឹងធ្វើឲ្យនិយមន័យនេះមិនអាចជាទីគាប់ចិត្តនោះទេ។

IV. **សេចក្តីសន្និដ្ឋាន**

22. អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលត្រូវបានអនុវត្តជាធរមាននៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការណាមួយប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធខ្លួនឯងអាចចាត់ទុកជាការវាយប្រហារសំដៅធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិលយោងតាមគោលបំណងនៃមាត្រា ៥ នៅក្នុងច្បាប់ អ.វ.ត.ក មិនថាក្នុងពេលសន្តិភាព ឬ ក្នុងជម្លោះប្រដាប់អាវុធនោះទេក្នុងករណីដែល៖ (i) ឧក្រិដ្ឋកម្មនោះគឺជាការធ្វើទុក្ខបុកម្នេញ ឬ (ii) សមាជិកនៃកងកម្លាំងប្រដាប់អាវុធគឺជាជនរងគ្រោះនៃការវាយប្រហារក្នុងទ្រង់ទ្រាយទូលំទូលាយសំដៅធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១៩ ខែឧសភា ឆ្នាំ ២០១៦ | Catherine Drummond | ទីក្រុងប៉ារីស | *ហត្ថលេខា* |
| | Philippa Webb | ទីក្រុងឡុងដ៍ | *ហត្ថលេខា* |
| | Dapo Akande | ក្រុងអុក្សហ្វត | *ហត្ថលេខា* |

[46] *Kayishema និង Ruzindana សាលក្រម* ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ ១២៧។